តើកូនរបស់អ្នកនឹងមានអាយុ នៅ 5 ឆ្នាំ ត្រឹមថ្ងៃ ទី 31 ខែសីហា មែនឬទេ?

ប្រសិនបើមែន ឥឡូវនេះដល់ពេល ចុះឈ្មោះចូលមត្តេយ្យសាលាហើយ!

**ទទួលជំនួយ** ក្នុងការចុះឈ្មោះ។ សូមទៅកាន់សាលាក្នុងតំបន់ ឬការិយាល័យមណ្ឌល។

# ការចុះឈ្មោះចូលមត្តេយ្យសាលា សន្លឹកព័ត៌មានស្តីពីឯកសារ

នៅក្នុងគ្រប់មណ្ឌលនៃគម្រោងផែនទីផ្លូវ (Road Map) ឯកសារខាងក្រោម ត្រូវបានប្រើប្រាស់ក្នុងពេលនៃដំណើរការចុះឈ្មោះ៖ ប្រសិនបើអាច សូមយកឯកសារទាំងនេះមកជាមួយអ្នក ដើម្បីជួយឲ្យការចុះឈ្មោះកូនរបស់អ្នកដំណើរការទៅបានរលូន។ ប្រសិនបើអ្នកមានសំណួរអំពីឯកសារទាំងនេះ មណ្ឌលសិក្សាធិការរបស់អ្នក នៅរង់ចាំជួយអ្នក។

- **ភស្តុតាងបញ្ជាក់កំណើត***
- **បណ្ណចាក់ថ្នាំបង្ការ** (ជំងឺអុតស្វាយ, កញ្ជ្រិល, ស្រឡទែន, ស្អូច, គ្រុនស្វិតដៃជើង, រោគខាន់ស្លាក់, តេតាណូស, ជំងឺរលាកថ្លើមប្រភេទ B, ក្អកមាន់)
- **ភស្តុតាងបញ្ជាក់អាសយដ្ឋាន** (កិច្ចសន្យាជួល ឬទិញ(ផ្ទះ), ឯកសារទីភ្នាក់ងារសាធារណៈ, វិក្កយបត្រទឹកភ្លើង)
- **ព័ត៌មានទំនាក់ទំនងគ្រាអាសន្ន**

ក្នុងមណ្ឌលខ្លះ ព័ត៌មានបន្ថែមទៀតត្រូវបានស្នើសុំ៖

** Kent និង Seattle មិនតម្រូវថាត្រូវតែមានសំបុត្របញ្ជាក់កំណើតទេ ប៉ុន្តែត្រូវមានឯកសារផ្លូវច្បាប់ណាដែលមានឈ្មោះសិស្ស និងថ្ងៃខែឆ្នាំកំណើត ដូចជាលិខិតឆ្លងដែន ឯកសារតុលាការ អត្តសញ្ញាណបណ្ណរដ្ឋ Washington State ឯកសារសុំកូន ។ល។ ឯកសារត្រូវតែមានបញ្ជាក់អត្តសញ្ញាណនិងអាយុ។*

| Seattle | Tukwila |
|---|---|
| • ព័ត៌មានទំនាក់ទំនងគ្រាអាសន្នសម្រាប់មនុស្សពីរ(2)នាក់<br>• ឯកសារពីរ(2)ខុសគ្នាដែលបង្ហាញភស្តុតាងបញ្ជាក់អាសយដ្ឋាន ចុះកាលបរិច្ឆេទក្នុងរយៈពេល 8 សប្តាហ៍ចុងក្រោយ | • បណ្ណសម្គាល់ខ្លួន (ID) ឪពុក/ម្តាយដែលមានរូបថត |

ទូរសព្ទទៅបណ្តាញទូរសព្ទសុខភាពគ្រួសារ (Family Health Hotline) តាមរយៈលេខ

**1-800-322-2588**

ដើម្បីទទួលជំនួយក្នុងការរកមណ្ឌលសិក្សាធិការរបស់កូនអ្នក

Start Strong | STEM Strong | Stay Strong

Road Map Region **RACE to the TOP**